# ពាលបណ្ឌិត



B-2
D-82
N-2903

ថ្ងៃ ៣៣-៧-៥៥១

[illegible]
[illegible]
[illegible] ............
[illegible] ............
លេខបញ្ជី ............

R - L 9 - 3 - 56

# រឿងពលឯក ខ្មែ ៣

អាចារ្យ

វង់ - ឈឹន

រៀបរៀង

ARCHIVES NATIONALES REGIE DU DEPOT LEGAL

ARCHIVES NATIONALES
COTE 82
B-107-1260

បណ្ណាគារ ជឹង ងួន ហួត លេខ ៣០ សួន

វិថីប៉ាស្ទ័រ

ខាងកើតផ្សារធំថ្មី ក្រុងភ្នំពេញ

បោះពុម្ពផ្សាយ

២៤៩៨

១៩៥៦

# រឿងពលឯក ខ្សែ៣

ខ្ញុំសូមថ្វាថ្ងៃនៃតនសោ ក្តី    ចូលក្នុងខ្សែបីនេះឯងណា
តពីខ្សែពីរអង្គក្សត្រា    ច្បាំងឈ្នះអសុរយក្សហោរហៅ ។
មហាផាលអសុរបុត្រស្លាប់បង់    បិតាមហាមេឃដែលរស់នៅ
បំណុះបុះចាញ់ក្សត្របមចៅ    បានទ្រង់គង់នៅដីពជន្មា ។
កាលអឺយៗកាលព្រះបមពង្ស    មានបុទ្ធីរង្គីវង្សថ្ងៃថ្វា
ពួកពលអសុរីល្បីបេស្តា    ខ្ញុំបង្ខាចវន្ទាព្រះបារមី ។
ថ្វាយខ្លួនធ្វើជាអង្គសេនា    បំរើក្សត្រាព្រះនរបតី
ថ្វាយកោះគិរីពជបុរី    ថ្វាយទឹកថ្វាយដីព្រៃព្រឹក្សា ។
ព្រះបាទឯកាបមចក្រី    ទទួលសិរីពីយក្សា
ស្តេចទ្រង់ប្រគល់ព្រះសីមា    ឲ្យអនុជាសោយ៍រាជ្យគ្រង ។
គ្រងកោះគិរីទិយក្សយេស    ប្រគល់ទាំងអស់អនុជស្នង
យក្សជាសេនាក្សត្របាស់ច្បង    ទ្រង់សោយរាជ្យគ្រងបុរីរម្យ ។
សុខសាន្តឥតមានមោះមន្ទិល    សព្វអស់សុរិលព្រះបរម
ស្តេចទ្រង់គង់លើទីបន្ទំ    សោយសុខមនោរម្យឥតទុក្ខភ័យ ។
ថ្ងៃពីបមពង្សអង្គឯកា    ព្រះរៀមដេផ្លាក្សត្រថ្វាថ្ងៃ

ស្តេចទ្រង់សោយរាជ្យអង់អាចក្រៃ　ក្រុងពេជ្របុរីរាជ្យសីមា ៗ
នឹងព្រះមហេសីស្រីបទុម　ចន្ទន៍ពេញក្រមុំរូបថៃថ្លា
ដំពើបបានបុត្រស្រីចម្បា　កន្ត្រាត្របះស្រឡះខែង ៗ
ទ្រង់ព្រះមនោមៀនមហេសី　ស្នេហាបេតីឥតបម្បែង
រីករាយព្រះទ័យដ៏ក្រៃលែង　ដោយឥតមានក្រែងអាង់ចេស្តា ៗ
ស្តេចទ្រង់ប្រលោមព្រះមហេសី　ចន្ទន៍បទុមស្រីដោយស្នេហា
ទ្រង់មានបន្ទូលស្រួលវាចា　ជាតៃកនិដ្ឋាព្រលឹងបង ៗ
កាលបងយាត្រាចេញពីស្រុកទៅ　រៀមនឹកប្អូនពៅពេកកន្លង
នឹកចាំងមាតាបិតាផង　នៃណាជន្ទនល្អឥតឧបមា ៗ
បងគន់មើលកន្ត្រង់ផ្ទូផង់　វង់មូលក្រឡង់ដូចចន្ទ្រា
សំឡេងស្រីបស្រួចដូចសារិកា　គួរឲ្យស្នេហាចាប់ចិត្តពេក ៗ
កាយអើយកាយល្អទន់សាច់ខ្ចី　កន្ទក់រាជ្យបុរីល្អចំឡែក
ក្លិនអើយក្រអូបពិដោពេក　គួរឲ្យតម្រេកដល់នាសា ៗ
រូបអើយរូបល្អគួរផ្តេកផ្តិត　គួររក្សារម្យរិតជិតកាយា
សុដន់ទាំងពីរជាប់ខ្ពាប　ដូចផ្កាបទុមក្រពុំរីក ៗ
ខ្ទិនអើយខ្ទិនដូចគន្ធបុប្ផា　គួរឲ្យចេតនាចាប់ចិត្តត្រេក
បង់ជួបរួបជិតរិតតម្រេក　ស្រែកខ្ញុំងស្រាំងខ្លួនន្ទនក្លួមស្រី ៗ

ព្រះហស្តទាំងសងក្រកង់ស្ងួន ក្រគាកស្រីនួនដូចសំឡី
ក្រសួលដូចបណ្ដូលចេកខ្ចី លើក្រៃពំនូខៃនសុវណ្ណ ៗ
សំពន់ក្បូត្រើយស្រីវិលក្ខណ៍ ហឫទ័យស្មោះស្ម័គ្រទឹកក្សត្រា
ស្ដេចភ្ញើចអម្ពរសុវណ្ណ នាងភ្ញើចអស្សុពារិឡ្ហមាត្យ ៗ
កើតមានអស្ចារ្យមហាម្ករធំ ចូលក្នុងជ្រោះក្នុំខ្វាយទឹកព្រាត
ខ្ញុចក្រែងដុះត្រង់ច្រាំងព្រាមៀត សង្កៀតសង្កឹនសង្កត់ទ្រម ៗ
មានផ្កែកបន្ទោក្ដិក្រែត ៗ អស់កាមហួតយៃគហុយទ្រលោម
ម្ករក្អែពិសចោលនៅខាងក្រោម រញាមរញ្ញួររកៈគាករិញ ៗ
ប្រគៀកប្រកិតរិតព្រះកាយ ជួញជិតគិតស្ដាយមិនអស់អញ
ដោយចិត្តប្រតិព័ទ្ធក្តីស្រឡាញ់ ខ្វលខ្វាញខ្ចីឃ្វាតឃ្វាតមិនបាន ៗ
នាងមានសវនីយ៍ស្ដីចរចា ទឹងអង្គក្សត្រាស្វាមីប្កាន
ខ្ញុំល្អងធូលីព្រះអវគាន បានក្សាន្តព្រោះក្សត្រិយ៍ខត្តិយាវង្សៗ
ឆោមអើយឆោមស្រស់កំឡោះស្អាត គ្មានអ្នកឯទៀតស្មើពូជពង្ស
ខ្ញុំម្ចាស់សូមលើកអញ្ជលីធ្ងន់ បង្គំដល់អង្គព្រះស្វាមី ៗ
បពិត្រទ្រង់ប្ចុត្តព្រះចេស្ដា សូមពានមេត្តាត្រាប្រណី
សន្ដោសខ្ញុំនប្អូនសួនជាស្រី អភ័យអត់ទោសប្រោសដល់ខ្ញុំ ៗ
កាលព្រះបមពង្សអង្គចក្រី ស្ដាប់ព្រះសវនីយ៍ស្ដីរម្យទំ

ព្រះឱស្ឋប្រែមញញឹមសម ខំប្រឹងចាំស្តាប់សព្វកថា ៗ
ព្រះនាងក្រាបទូលថាបពិត្រ ព្រះពៅទ្រង់ឫទ្ធិបមដេជ្ជា
ប្អូនសូមផ្ញើខ្លួនលើកស្តា ព្រាថ្នាឲ្យជួបគ្រប់ ៗ ជាតិ ៗ
ឲ្យបានព្រះបងជាស្វាមី រួមមេត្រីកុំបីឃ្លាត
សូមកុំឲ្យអ្នកដទៃទៀត មកបៀតទៀតបានព្រាណខ្ញុំឡើយ ៗ
កាលព្រះឯកាចក្រពត្តិ គប់នឹងបន្ទូលស្រីបទុមហើយ
ថាឱថ្លៃថ្លើមឆ្នើមជាត្រើយ ប្អូនអើយសូមឲ្យជួបប្រាថ្នា ៗ
រឿងនេះឈប់ស្ទះបង្អង់ស្តី ថ្លាថ្លែងសេចក្តីពីមាតា
បិតាដែលនៅក្នុងព្រឹក្សា អាល័យបុត្រាទាំងពីរពង្ស ៗ
ព្រាស់ព្រាត់បែកបាក់យូរអង្វែង ករណ្តាចកណ្តងចម្បែងអង្គ
ពុំរុងដំណឹងបាត់សូន្យសុង ឱប្រុសឆោមយង់ថ្លៃម្តាយអើយ ៗ
កូនប្រុសទៅបាត់ឥតដំណឹង អ្នកទៅទាំងខឹងនឹងម្តាយហើយ
មិនឃើញត្រឡប់វិលវិញឡើយ ស្លាប់ហើយឬមួយអ្នករស់នៅ ៗ
ម្តាយខំដើររកអ្នកក្នុងព្រៃ ឮសូរសត្វរែកក្នុងព្រៃជ្រៅ
ខំប្រឹងត្រាច់កាត់សំដៅទៅ ស្មានជាកូនពៅស្រែកហៅម្តាយ ៗ
កូនអើយអើកូនប្រុសពន្លក ម្តាយខំដើររកក្នុងព្រៃឆ្ងាយ
គោតចិត្តកូនប្រុសដាច់ពីម្តាយ ពុំដែលឃ្លាតឆ្ងាយមួយវេលា ៗ

ស្វាមីពុំនាំជាប្រពន្ធ    សោយសោកពេកពន់ក្នុងព្រឹក្សា
អង្វរប្រពន្ធជាកនិដ្ឋា    ប្អូនកុំសោកាណាថ្លៃបង ៗ
បើកូនយើងមានភ័ព្វសំណាង    មិនស្លាប់ទេនាងស្រស់នួនល្អង
គង់បានជួបជួនបុត្រស្ងួនគ្រង    មាសបងចូរបាត់ស្ងាត់យំទៅ ៗ
នាងសង្រេងបុត្រនៅតែធ្អឹង    ខ្លួនស្គមកំព្រឹងរឹងសោកសៅ
បរិភោគពុំបានប្រាណរីងក្តៅ    នឹកណាស់បុត្រពៅនៅតូចពេក ៗ
សម្រក់ទឹកភ្នែកជោកនេត្រា    ពេលបរិភោក្តានាងក្រឡេក
ពុំឃើញបុត្រាផ្សាទុរេក    បង្អៀតតឹងពេកស្ទើរបែកធ្លាយ ៗ
ថ្លែងថាឱបុត្រថ្លៃពន្លក    មិនគួរអ្នកមកបែកព្រាត់ព្រាយ
នឹកអ្នករាល់ពេលគ្មានរសាយ    កម្មកាយម្តាយអីក៏ដល់ម៉្លេះ ៗ
ឱ ! ប្រុសតាំងពីរថ្ងៃម្តាយអើយ    ម្តេចឡើយពន្លកមករបេះ
ពីទ្រូងម្តាយទៅពៅរលេះ    មិនបេះរលឹកនឹកមាតា ៗ
សោយសោកជ្រួលជ្រប់សន្ធប់លង់    ក្នុងព្រះព្រៃព្រឹក្សពុំបរបា
បង់បាត់ស្មារតីស្រីកល្យាណ៍    ព្រោះប្រាស់បុត្រាតាំងពីរប្រាណ ៗ
ស្វាមីឃើញស្រីស្រស់និមល    កាយកបដួលដល់ផែនដីបាន
ស្ទុះទៅត្រកងស្រីកល្យាណ    ចូរក្រោកឡើងថ្កានព្រលឹងបង ៗ
សុរិយេទន្ទេរជ្រៀបទៅ    ក្រោកឡើងតោមផ្ទៅស្រស់នួនល្អង

ត្រឡប់វិលទៅផ្ទះយើងផង ក្រែងមានសៅហ្មងក្នុងព្រៃជ្រៅ ។
ដ្បិតក្នុងព្រៃនេះច្រើនតែសត្វ វាតែងត្រេចគាត់ទីលំនៅ
ក្រែងជួបប្រទះសត្វសាហាវ ក្រោកឡើងប្អូនពៅទៅត្រិះស្ពាន ។
លង់លុះព្រលប់យប់សន្ធ្យា នាងបានដឹងស្មារតីកល្យាណ
ដើរតាមស្វាមីវិលវិញឋាន ដល់ផ្ទះទីស្ថាននៃអាត្មា ។
សោកបុត្រទាំងពីរអស់ឆ្នាំបី ស្ត្រីស្គាំងស្គមស្រមកាយា
ណាព្រួយនឹងអត់ស្បៀងអាហារ ខ្វះបរិភោគគ្រាពល់វេលា ។
ណាគ្មានសំពត់នឹងស្លៀកពាក់ បេះស្លឹកខ្ទុំតែងមកពាត់ពា
កាច់បន្ទាខ្លាសំរុំកាយា គួរឲ្យអនិច្ចានាងក្រែពេក ។
មានកាលសម័យថ្ងៃមួយនៃ ប្រពន្ធនឹងប្ដីទូលហើយរែក
ខុសនឹងស្លឹកឈើច្រើនអនេក យកទៅលក់ចែកឲ្យអ្នកស្រុក ។
អ្នកខ្លះឃើញហើយលាន់មាត់ថា ទុះទុ អនិច្ចាពុំសមមុខ
ស្លៀកអ៊ីមអ៊ឹង ៗ ដូចសម្បុក អង្រឹងធ្វើទុកលើព្រឹក្សា ។
ពាស់ក្មេងចោមរោមមើលភ្លូកភ្លឹក នាងនឹកអៀនអន់ក្នុងទ្រវា
ហេតុតែស្រេកឃ្លានគ្មានអាហារ នឹកថាទុកម្ដាព្រេងនាយ ។
អំពើខ្លួនធ្វើតែងជូនមក នេះហើយត្រូវយកគឺសំពាយ
ប្រឹងប្រែងស្មារតីមិនរាយមាយ ទំប្រឹងខ្វល់ខ្វាយកាត់អៀនខ្មាស់ ។

អ្នកស្រុកខ្លះយកខុសមួយបាច់ ខ្លះយកបន្ទៃទាំងក្រេងចាស់
អាណិតអ្នកក្រកំសត់ណាស់ ខោអាវចាស់ៗឲ្យថែមទៀត ៗ
ខ្លះឲ្យប្រហុកឲ្យអំបិល ខ្លះឲ្យអំពិលនឹងត្រីងៀត
ផ្តាំថាក្រោយៗនាំមកទៀត ខ្លះធៀតឲ្យស្រូវឲ្យអង្ករ ៗ
ខ្លះសួរនាងថានាងឈឺអ្វី បានជាស្តើស្គមអ្វីម៉្លេះនេ៎
ដូចគ្មានអាហារក្នុងឧទរ នឹងឈាននឹងឈរស្ទើរពុំបាន ៗ
ប្អូននាងប្រាយប្រាប់ឲ្យយើងដឹង គ្រាន់ជាដំណឹងណាកល្យាណ
នឹងជួយរកថ្នាំសង្គ្រោះប្រាណ ឲ្យបានសុខសាន្តអង្វែងទៅ ៗ
ទើបនាងប្រាយប្រាប់អ្នកស្រុកថា រោគខ្ញុំនេះណាចេះតែក្តៅ
ដាំងបីឆ្នាំហើយកូនព្រាត់ទៅ ខ្ញុំចាំមើលផ្លូវពុំឃើញឡើយ ៗ
រោគអ្វីដទៃគ្មានឈឺសោះ ខ្ញុំចេះតែអស់កំឡាំងស្បើយ
ខ្ញុំដេកពុំបានណាអ្នកអើយ អង្វែងឆ្នាំហើយគ្មានភ្លេចសោះ ៗ
កូនប្រុសទាំងពីរឃ្លាឃ្លាតទៅ បើនៅឥឡូវពេញកំឡោះ
ចេញចោលខ្ញុំទៅគ្មានស្រណោះ ក្នុងពោះពោរពេញដោយទុក្ខា ៗ
បានជាខ្ញុំស្គមទ្រមងៃ ទាំងប្រពន្ធប្តីណាអ្នកណា
លំបាកគោកយ៉ាកក្នុងកាយា ប្រាស្រ័យព្រឹក្សាធ្វើជាញាតិ ៗ
និយាយសារសាប់ប្រាប់អ្នកស្រុក អំពីរឿងទុក្ខដែលអាពាធ

គ្មានពេលឯណាដទៃទៀត　មកបៀតរុករានទទ្រូនានឡើយ ។
អ្នកស្រុកស្តាប់ហើយរឹងអាណិត　អាសូរដល់ចិត្តនាងឥតស្បើយ
ប្រាប់ថានាងអើយកុំសោកឡើយ　បុណ្យមានគ្រាក្រោយបានជួបវិញ ។
ស្រួចហើយនាងលាអ្នកស្រុកមក　ចាប់កញ្ជើក្រោកទូលពោរពេញ
ប្តីគេអម្រែកលើស្មាចេញ　ពីស្រុកគេមិញសំដៅព្រៃ ។
ជាទីលំនៅផ្ទះអាត្មា　ដល់ស្រួចកាលណានាងស្រីថ្លៃ
បំអិនអាហារឆ្អិនឆាប់ក្រៃ　ដួសឲ្យស្វាមីបរិភោគ្គា ។
រីឯបុរសប្តីប្រពន្ធ　សូមសង្ខេបសិនលែងចរចា
ខ្ញុំសូមចាប់ចែងពីក្សត្រា　ទាំងពីរអង្គាស្រុកយក្សនៃ ។
ព្រះរៀមទ្រង់សោយរាជសម្បត្តិ　សម្បូរពេកក្តាត់ពេជ្របុរី
មនោរម្យយក្សអគ្គមហេសី　នាមចន្ទបមស្រីបទុមា ។
ឯព្រះអនុជពៅឱរស　សោយរាជ្យនៅកោះគិរីណា
គ្រប់គ្រងស្រីស្នំក្រុមបរិវារ　យក្សជាសេនាច្រើនក្រាស់ក្រៃ ។
សឹងតែខ្លបខ្លាចអំណាចបុណ្យ　បារមីលើសលន់ត្រប្រពៃ
ខេត្រចងឯងផងជម្ងឺភ័យ　គ្មានស្តេចដទៃហ៊ានប្រមាថ ។
ទើបស្តេចប្រជុំយក្សសេនា　មហាមេឃអសុរជាដើមអាទិ៍
ស្តាប់ព្រះបន្ទូលក្សត្រក្សត្រានាថ　ស្តេចទ្រង់យាងយាត្រាពេជ្របុរី ។

ឯនាងរៀបពលរេហ៍ជូនយើងទៅ គាល់ព្រះចមចៅជាជេដ្ឋា
អាមាត្យរៀបតាមព្រះបញ្ជា ក្រាបទូលក្សត្រាប្រាបហេតុទ័យ ៗ
យាងចេញចាកទីគិរីកោះ គង់លើយក្សយសហោះច្រៀវព្រៃ
ឆ្លងសមុទ្រពិគិរីព្រៃ ដល់ពេជ្របុរីដូចប្រាថ្នា ៗ
ចរចុះចូលក្នុងព្រះរាជវាំង ឡើងគង់លើប្រាង្គមាសថ្ងៃថ្លា
ទ្រង់ថ្វាយបង្គំព្រះជេដ្ឋា ទូលស្នើកិច្ចការសព្វសេចក្តី ៗ
បពិត្រចមចក្រព្រះចៅបង សូមទានទោសផងប្រោសប្រណី
ក្រែងសំទិងគួរលើសខ្វះក្តី ប្រណីមេត្តាទោសាខ្ញុំ ៗ
សូមទូលដំណាលកាលទំនង ដំណើរដើមទងព្រះបរម
មានខសន្យាទីប្រជុំ ផ្តាជ្ញាទឹងខ្ញុំថាបីខ ៗ
លើកពលទៅតាមព្រះជនទី ជនកទាំងពីរដែលលោកថៃ
មានគុណមហាធ្ងន់លើយើងដែរ ស្មើក្ពុំព្រះសុមេរុសមុទ្រជ្រៅ ៗ
ហេតុនេះសូមទ្រង់ប្រោសមេត្តា ព្រះរៀមជេដ្ឋាស្តេចយាងទៅ
ម៉្វេះសំមាតាអ្នកក្តួលក្តៅ រស់នៅឬស្លាប់ជន្មជីវិត ៗ
កាលព្រះរៀមរក្សាក្រាក់ស្មារតី ពុអនុជស្តីពីនោះពិត
ទ្រង់ព្រះញញឹមខិតចូលជិត ប្អូនគិតត្រូវហើយព្រលឹងបង ៗ
គិនិតប៉ុនប៉ងបងសព្វថ្ងៃ នឹកមាតាថ្ងៃពេកកន្លង
ចំណែកប្អូនគិតដូចចិត្តបង កុំឲ្យកន្លងពាក្យសច្ចា ៗ

ដូចនេះគួរតែយើងចេញទៅ បុរីពជ្រមជ្រងសីមា
ជួបជុំមហេសីទាំងទ្វេហា ទាំងអនុជាទាំងបងផង ៗ
មូលមិត្តនគរយើងទាំងពីរ ចង់យកនារីស្រស់នួនល្អង
ចន្ទ៌បទុមានេះទៅផង នឹងដូចបំណងនាងប្រាថ្នា ៗ
អនុជក្រាបទូលថាបពិត្រ ព្រះពៅទ្រង់ទ្វិចមជេដ្ឋា
បើស្តេចយកអង្គព្រះធីតា ទៅផងកាលណាប្រសើរក្រៃ ៗ
នៃអនុជប្អូនក្រែងថ្ងៃមុខ នឹងមានកើតទុក្ខដល់ដួងថៃ
កើតមានប្រច័ណ្ឌដល់កិសម័យ មហេសីថ្វាថ្ងៃឯនគរ ៗ
ហេតុនេះដំរិះគិតដូចម្តេច នឹងបានសម្រេចសេចក្តីល្អ
សុខចិត្តសុវណ្ណស្រីអម្ពរ ស្រុះស្រួលឧបអរនឹងប្អូនស្រី ៗ
ទើបព្រះអនុជទ្រង់ទូលថា បពិត្រក្សត្រាមានបារមី
បំណែកខាងចន្ទ៌បទុមស្រី ថ្វាយព្រះសវនីយ៍ជាប្អូនធម៌ ៗ
ឧបាយបែបនេះទើបងាយដោះ រួចខ្លួនទាំងអស់នឹងបានល្អ
សុខចិត្តទាំងអស់ព្រោះស្មោះស ឧបអរសាទរស្រឡាញ់គ្នា ៗ
សម្តេចព្រះរៀមសួរអនុជ ថាបើមហេសីជ្រាបកិច្ចការ
ថ្ងៃក្រោយទៅទៀតថ្ងៃនេះក៏ រួមទីសុវណ្ណាបទុមស្រី ៗ
ឆ្លើយថារៀមបងជួយកំដ ធម្មតាប្អូនធម៌ដែលមកថ្មី
ក្រែងនាងញញើតក្នុងរាត្រី នៅក្មេងសេចក្តីឆ្លុសពុំបាន ៗ

អនុជផ្ដោះសារសព្វសេចក្ដី ទូលព្រះបក្រីជារៀមថ្កាន
ព្រះចៅត្រេកអរផុតតំខាន បានក្សាន្តព្រះទ័យនិរាសទុក្ខ ៗ
ទ្រង់មានបន្ទូលនឹងមហេសី បន្ទន់បទុមស្រីបំពាះមុខ
ប្អូនស្រីនាងនៅឲ្យបានសុខ កុំបីជាទុក្ខណាកែវណា ៗ
ស្ដេចល្បងលង់ចិត្តបន្ទន់បទុម តើនាងនឹងឆ្លើយដូចម្ដេចម្ដា
ចង់ដឹងកលកិច្ចកែវកែនិដ្ឋា ដីរ៉ានាងតាមប្ដូដូចម្ដេច ៗ
ទើបនាងឆ្លើយតបថាបពិត្រ ព្រះចៅទ្រង់រិទ្ធិ៍លើសសម្រេច
ព្រះអង្គចោលខ្ញុំទ្រង់វេះគេច គួរម្ដេចចោលខ្ញុំឲ្យកំព្រា ៗ
ខ្ញុំស៊ូតែស្លាប់ក្រោមព្រះបាទ សូមព្រះភូវនាថទ្រង់មេត្តា
នៅម្ដេចវង់ទុក្ខមុខវេទនា គ្មានគ្នាជួបខ្មោចអាសោចឈ្មោះ ៗ
ហៃបន្ទន់បទុមផ្ដុំខ្ទិនឈ្មេង បងដឹងប្អូនឯងចិត្តស្ម័គ្រស្មោះ
បើនាងចង់ទៅក៏ទៅចុះ សោះបងវិលទឹកមកស្រី ៗ
ចូរនាងរៀបខ្លួនទឹមនួនស្រស់ ស្លៀកពាក់ព្រំប្រស់របស់ថ្មី
អម្ពរខិមខាត់ស្រស់ទៀវខ្ចី ចេញទៅបូរីនាយនឹងបង ៗ
ទាំងបីព្រះអង្គទ្រង់ស្អាងកាយ រូបឆោមឆើតឆាយផ្សាយពញ្ចង់
ស្មើត្របះស្រឡះទ្រង់ ដូចអង្គទេវបុត្រប្យុតលា ៗ
ចុះចាកប្រាសាទស្អាតកិរម្យ ឡើងថ្វាយបង្គំព្រះបិតា
ស្រេចហើយក្រាបទូលសព្វកិច្ចការ លាទាំងមាតាក្សត្របមពង្ស ៗ

កូនសូមក្រាបលាទៅនគរ　　សីមាបវរដ្ឋរឿងរង
យកបន្ទូលបទុមអនុជណាង　　នាំចូលទៅក្នុងបុរីនាយ ។
ឲ្យបានស្គាល់ទីស្ថានលំនៅ　　ស្រុកទេសម៉ែឪរៀងកល់កាយ
មូលមិត្តញាតិជិតដូចនឹងម្ដាយ　　សប្បាយដឹងទុក្ខដឹងសុខគ្នា ។
ហេតុនេះសូមទ្រង់ប្រោសប្រណី　　ឲ្យកូនទាំងបីបានសុខា
ប្រកបដោយគុណបុណ្យសីលា　　តេជះបិតាមាតាផង ។
ទើបក្រុងអសុកបីតាថ្លែង　　ថាឲ្យកូនឯងប្រកបហោង
កុំឲ្យអន្តរាយភ័យទុក្ខផង　　បៀតបៀនឡើយហោងទាំងអស់គ្នា ។
សូមឲ្យអ្នកបានសុខសប្បាយ　　ទ្រព្យធនទាំងឡាយសព្វបរិវារ
អាយុយឺនយូរយេវស្សា　　កុំបីឃ្លាតណាដូច ១ បង ។
ទៅចុះកូនស្រីកុំបីឃ្លាត　　រក្សាមារយាទកុំឲ្យហ្មង
ប្រណិបតន៍ស្វាមីកុំបីឆ្គង　　កុំឲ្យកន្ទ្រង់ច្បាប់មាត្រា ។
ទាំងបីអគ្គាលាស្រេចហើយ　　ប្អូនអើយយើងចេញចាកសេមា
មិនបាច់យកពលយក្សសេនា　　នាំឲ្យមនុស្សគិតភ័យខ្វល់ ។
សម្ដេចព្រះរៀមយកកន្សែង　　មកបក់ថ្វាថ្លែងតែងជាថ្នល់
កើតបានជារថអស្សព្រាហ៍ផល់　　ចូលមកជុំជាល់នឹងព្រះអគ្គ ។
រាជរថមាសសុទ្ធល្អស្អាត　　ទឹមដោយអស្សព្រាហ៍ស្អាតគ្រប់
ក្សត្រាក្សត្រីបីព្រះអគ្គ　　ឡើងគង់លើរថមាសថ្លៃថ្លា ។

សំដៅទៅវត្តរាជបុរី ក្រុងពារាណសីព្រះសោមា
តាមដោយវិថីគិតគណនា ផ្លូវឆ្ងាយចម្ងាយសាមសិបយោជន៍ ៗ
ផ្លូវវែងអន្ទាយឆ្ងាយលន្ទឹម ណើរថទន្ទឹមវែងលន្ទោច
បររថមួយថ្ងៃបានដប់យោជន៍ ស្រណេះស្រណោចក្នុងព្រឹក្សា ៗ
មើលដើមព្រៃព្រឹក្សព្រឹព្រួចកាយ គួរឲ្យរីករាយក្នុងកាយា
ព្រះហស្តចង្អុលប្រាប់កនិដ្ឋា ធីតានាងទតលេងសប្បាយ ៗ
ព្រឹក្សាផុះចារជាផ្លូវដិត ស្លឹកខៀវងងិតផ្ការីករាយ
ទស្សនាទតលេងបាត់ខ្វល់ខ្វាយ ទាំងបីព្រះកាយកើតសោមនស្ស ៗ
ហើយទ្រង់ទតទាំងឆ្នេរស្រះស្រី មានឈូកខៀវខ្ចីពេញទាំងអស់
មានសែតក្រហមនៅចម្រុះ ដុះលាយទាំងអស់សុទ្ធសឹងផ្កា ៗ
ប្អូនមើលព្រលូងពាំព្រលឹត ដូចបងប្រកិតប្រកៀកណា
មើលចង្កលណីដូចបងចារ បងកែវកនិដ្ឋាឲ្យជាប់ចិត្ត ៗ
ផុតព្រៃដួចចូលបុរនគរ សោមាបវរប្រសើរពិត
សម្ដេចព្រះរៀមស្ដេចទ្រង់រិទ្ធិ វិចិត្រប្រាប់ថាហៃប្អូនស្រី ៗ
នេះហើយស្រុកទេសនគរបង នួនល្អងហៅថាពារាណសី
បងមានទាំងអគ្គអគ្គមហេសី ក្សត្រីយ៍ឧត្តមសុវណ្ណា ៗ
ហៃនួនស្រស់ស្រីចន្ទ្របទុម គ្រសាយគ្រសុំខ្ចីដូចផ្កា
ដួចមហេសីដើមបងកាលណា កនិដ្ឋាសុំពះវរក្សត្រី ៗ

នាងទូលគតិនទេពីបង　　អញខ្ញុំនេះហានប្អូនជម៌ថ្មី
ជាបុត្រអសុរពេជ្របុរី　　កុំឲ្យក្សត្រីអន់ចិន្តា ។
លង់លុះយូរទៅនាងដឹងហេតុ　　ដឹងកេទប្អូនស្រីគ្រប់ប្រការ
ពោះបីនាងខឹងដូចម្ដេចម្ដា　　ចាំបងផានាគ្រប់កន្លែង ។
ក្រាបទូលសម្ដេចព្រះស្វាមី　　កុំព្រះចក្រីស្ដេចចម្បែង
ធម្មតាយើងចុងគេនេះឯង　　តែងតែទ្រចិត្តជាដ៏ពាប ។
ស្ដេចបរេថចូលក្នុងរាំងជ័យ　　នាហ្មឺនមន្ត្រីសឹងឱនក្រាប
សុវណ្ណអម្ពរក៏បានជ្រាប　　នាងរៀបខ្លួនចុះចេញចាកប្រាង្គ ។
មកដល់ស្វាមីថ្វាយបង្គំ　　លើកហត្ថប្រណម្យទើបព្រះនាង
ទូលសព្វសេចក្ដីតបរៀង　　ស្ទួរថានាងនេះមកពីណា ។
ចមចន្ទ៍បទុមជាអម្បូរ　　ព្រស្រស់អម្ពរសុវណ្ណា
មានសវនីយ៍ស្ដីស្ទួរថា　　ធីតាទូលសព្វគ្រប់សេចក្ដី ។
ខ្ញុំជាបុត្រីអសុរយក្ស　　សោយរាជ្យដៀងជាក់ពេជ្របុរី
ឯនាមសម្ដេចព្រះវរបី-　　តានោះឯងនៃវិរុឡ្ហមាត្យ ។
ព្រះនាមសម្ដេចវរមាតា　　ឈ្មោះវរចន្ទ្រានោះជាភាទិ
ខ្ញុំម្ចាស់ឈ្មោះចន្ទ៍បទុមជាតិ　　សូមព្រះនាងនាថជ្រាបសេចក្ដី ។
ខ្លួនខ្ញុំត្រូវជាប្អូនជម៌ជង　　សម្ដេចព្រះបងចមចក្រី
យកខ្ញុំមកលេងក្នុងបុរី　　ឲ្យស្គាល់មហេសីតរៀងទៅ ។

សុវណ្ណកុមារក្មេងនេះ　　បន្ទន់បទុមដោះពាក្យទៅពៅ
ប្រុបណ្ហាក្នុងចិត្តនាងស្រីពៅ　　ទឹកទៅមិនអស់ក្នុងចិន្តា ៗ
មនុស្សម្នាមហាជនមកពេញពាស　　ទាំងនាហ្មឺនពស្ត្រច្រើនត្រៀបត្រា
គន់មើលស្រីបន្ទន់បទុមា　　ហាក់ដូចទេវតាក្នុងស្ថានសួគ៌ ៗ
សំផាមហើយស្តេចសោយពង្ស　　ប្រសើរឯងអាចនោះទើបគួរ
រកស្រីឯណាមកស្មើតួ　　នេះពេញហៅគួរក្នុងបុរី ៗ
ទើបអគ្គសម្តេចព្រះអនុជ　　ក្រាបលាសម្តេចព្រះរៀមខ្ចី
ចង់ចេញទៅវត្តពង្សបុរី　　ដួបជុំមហេសីឯនាយណា ៗ
ទើបថ្លែងអំពីការទៅតាម　　ជនកជននីពារអគ្គា
ដែលលោកនៅក្នុងព្រៃព្រឹក្សា　　ម្ល៉េះសំវេទនាព្រួយលំបាក ៗ
កាលនោះព្រះរៀមថ្លែងនុក្ការ　　ប្រាប់អគ្គជាយាជាចេញចាក
ទៅតាមមាតាលោកតោកយ៉ាក　　ម្ល៉េះសំលំបាកព្រួយព្រះទ័យ ៗ
ទើបនាងអម្ពរសុវណ្ណា　　ទទួលនុក្ការក្សត្រដៀវស្ឋ័យ
បើហ្នោះឲ្យរៀបពលសេនីយ៍　　សព្វមុខមន្ត្រីធាប់រួសរ៉ា ៗ
យើងចេញពីក្រុងពារាណសី　　សំដៅបុរីសាកេតណា
ពួកពលអនុជច្រើនត្រៀបត្រា　　ដីតាមូលីស្រីសុន្ទរ ៗ
នាងបានទៅផងច្រើនមូលមិត្ត　　ជាំធ្មុំជិតពលកុះករ
សេនីយ៍សេនាច្រើនល្ហូរឆរ　　វិកវររទេះសេះដំរី ៗ

ជំនុំប្រែស្រេចស្តេចចេញចរ　　ចាកក្រុងបវរពារាណសី
ទាំងព្រះអនុជនិងមហេសី　　គង់លើដំរីគជេន្ទ្រា ៕
កួបចិតសឹងមាសប្រាសប្រាលឆ្អៅ　　សន្ធោសន្ធៅក្ដឹងអស្ចារ្យ
ពលសេះដិះសេះច្រើនត្រៀបត្រា　　ហែអង្គព្រះមហាក្សត្រចមទៅ ៕
រឿងនេះស្រូតរូតមិនហូរហែ　　គ្រាន់តែត្រួស ៗ បន្តិចទៅ
មិនបានពប់ឈើដើរតាមផ្លូវ　　មិនសូវចំណាំចាំបានផង ៕
ដើមត្រាច់បងនាំប្អូនត្រាច់ទៅ　　តាមម្ចាស់បងនៅក្នុងព្រៃហោង
ដើមឃ្លៃបងឃ្លាតមកយូរផង　　សុខទុក្ខម្ដេចបងពុំបានដឹង ៕
ករណ្ដាលះចោលនៅកណ្ដាលព្រៃ　　ម៉្លេះសំកិតក័យស្ងាត់ទ្រូឈឹង
ភ្លូកភ្លឹកស្មារតីក្លែបសូន្យឈឹង　　គ្មានទីពឹងអ្នកឯណា ៕
ឱ ដើមព្រីងព្រួសវៀមប្រាសព្រាត់　　បោះបង់ចោលបាត់ក្នុងព្រឹក្សា
ពុំដែលឃើញមុខអ្នកមាតា　　យូរឆ្នាំហើយណាអ្នកម្ដាយអើយ ៕
អន្ទាលខ្ញុំចោលអន្ទាលម៉ែ　　ដេរពោលបណ្ដៃបណ្ដោញហើយ
ដក់ពប្អូនពៅរត់តាមក្រោយ　　បណ្ដោយម៉ែគាត់គ្មានបណ្ដេញ ៕
ពន្លឺពីរឿងផ្លូវពលឯក　　បានជាបាក់បែកបែកបាកចេញ
គាត់ដេរហើយគាត់ថែមបណ្ដេញ　　វៀមវៃរត់ចេញចោលគាត់ណា ៕
ទ្រង់ហានបន្ទូលនឹងមហេសី　　យកដើមព្រឹក្សព្រៃប្រៀបឧបមា
ឲ្យនាងបានដឹងរឿងសាវតារ　　កាលពីកុមារតូចនោះឯង ៕

លុះបានចូលដល់ក្នុងនគរ　　សាកេតបវរជាកន្ទួង
នៃព្រះអនុជទ្រង់ចាត់ចែង　　តាក់តែងសេនាពលយោធា ៗ
ប្រាប់អស់នាហ្មឺនមុខមន្ត្រី　　ឲ្យរៀបសេនិយ៍ឆាប់រួសរ៉ា
ឲ្យទាន់ជម្រាស់គ្រាស់ទុក្ករ　　ទៅតាមមាគានៅក្នុងព្រៃ ៗ
អាមាត្យទទួលតាមបង្គាប់　　រៀបរួចស្រេចស្រាប់ទាន់ព្រះទ័យ
គ្រាស់ហៅមូលីសុន្ទរស្រី　　តែងក្លួឆាប់ខ្ចីគ្រឿងអម្ពរ ៗ
រៀបស្រេចឡើងគង់លើដំរី　　ក្នុងខៀវសខ្ចីសម្បុរល្អ
កូបបិតសឹងមាសថ្លៃបវរ　　ទ្រង់យាងចេញចរចាកសីមា ៗ
នគរទាំងពីរមកជួបជុំ　　ដង្គាលដង្គុំច្រើនត្រៀបត្រា
ពួកពលសេនិយ៍ទឹងសេនា　　ស្នំស្រីស្រីង្គាពាន់ហ្មឺនសែន ៗ
លុះបានទៅដល់មណ្ឌលព្រៃ　　ទាំងពីរក្សត្រថ្ងៃឈប់គដេទ្រូ
ឈប់ទាំងរេហ៍ពលពាន់ហ្មឺនសែន　　ចុះគង់ព្រះផែនសម្រាកកាយ ៗ
ក្បែរឆ្នេរស្រះស្រង់កំពង់ថ្លា　　ពួកពលសេនាត្រេកសប្បាយ
ឲ្យទឹកដំរីសេះទាំងឡាយ　　ខ្លះក្ដៅក្រហាយចុះងូតទឹក ៗ
ទាំងស្រីទាំងប្រុសចម្រុះគ្នា　　មុជក្នុងគង្គាសូរសន្ទឹក
ប្រឡូកប្រឡែងគ្នារអឹក　　ក្នុងទឹកខ្លះហក់ហែលច្រៀវច្រេ ៗ
ក្សត្រីយ៍ក្សត្រាយាងចុះស្រង់　　ទាំងប្រាំព្រះអង្គសប្បាយក្រៃ
ភីលៀងស្រីស្នំក្រុមសៅដៃ　　អាមាត្យមន្ត្រីទាំងអស់គ្នា ៗ

ខ្លះហែលដណ្ដើមផ្កាក្រមុទ   លោហក់ចាប់ផុតហែលប្រវ៉ា
ខ្លះបេះឧតបុលសៀតកម្ភា   ខ្លះថាលំបង់ស្បង់កាប់ផង ៗ
ខ្លះលេងកញ្ឆ្លោកបោកបាចទឹក   គគ្រេងគគ្រឹកសើចអឺងកង
ខ្លះដេញហែលចេញទៅត្រសង   បាចសគ្នាផងខ្លះចាប់ញៀច ៗ
ស្រង់ស្រេចសម្ដេចព្រះចក្រី   នាំអគ្គមហេសីអនុជនាថ
ឡើងចាកស្រះស្រីឈប់ប្រពាត   យានយាត្រគង់លើព្រះពន្លា ៗ
ពួកស្រីស្រឹគ្គាឡើងទាំងអស់   ពួកនាយគោជន៍កស្ដុលើកក្រយ៉ា
ថ្វាយស្ដេចទ្រង់សោយនូវអាហារ   លើព្រះពន្លាអមស្រះស្រី ៗ
សុរិយាអស្ដង្គតផុតនាទី   ចាំងជ្រុងគីរីសុមេរុខ្ចី
ព្រះចន្ទ្រចែងចាំងចេញរស្មី   បក្ខីលោកីយ៍ស្វាងព្រោងព្រាយ ៗ
ពួកយាមដុតភ្លើងភ្លឺព្រោងព្រាត   ចំប្រឹងយាមល្បាតគ្រប់នាយអាយ
ក្រែងមានសត្រូវពីជិតឆ្ងាយ   រាំមកមើលងាយព្រះចេស្ដា ៗ
យាមមួយយាមពីរដល់យាមបី   អរុណោទ័យស្វាងកាលណា
លុះដល់ព្រឹកព្រាងព្រះសុរិយា   ហែអង្គក្សត្រាចរចេញទៅ ៗ
សំដៅច័ន្ទគ្រាមជនបទណា   កន្លែងមាតាបិតានៅ
នាំអស់សេនាគ្រាប់ចូលទៅ   ទីស្ថានលំនៅក្បែរដងព្រៃ ៗ
ស្ដេចយាងមករកតាមមាគ៌ា   បើគិតគណនាបានខែ
ថ្ងៃទើបដល់មាតាថ្លៃ   ដល់ដែនដងព្រៃទីនោះណា ៗ

ទើបស្ដេចឲ្យឈប់ពលសេនីយ៍ ពលសេះដំរីនៅត្រៀបត្រា
ស្ដេចចូលទៅរកព្រះមាតា យានយាសយាត្រាសំដៅទៅ ។
រីឯមាតានឹងបិតា ព្រួសន្ធឹកណាក័យទៅហើ
នាំប្ដីប្រពន្ធរត់ចូលទៅ សម្ងំពួននៅទីស្ថានឆ្ងាយ ។
ចូលក្នុងរូងភ្នំស្ងាត់ទ្រឈឹង ស្ទើរបាត់ព្រលឹងទាំងពីរកាយ
ប្រឹងរត់ទៅពួនអត់ទាំងបាយ បេញឆ្ងាយពីផ្ទះនៃអាត្មា ។
ស្ដេចយាងចូលដល់មណ្ឌលស្ថាន ទាំងពីរក្សត្រក្សត្ដពុំឃើញណា
ឃើញតែកន្ទួងព្រះមាតា ក្សត្រាទ្រង់ព្រះកន្សែងសោក ។
ឱ! អ្នកមាតាម្ចាស់កូនអើយ អ្នកអើយឲ្យកូនកើតវិយោគ
ទៅណាបាត់ស្ងួនឲ្យកូនសោក សូមអញ្ជើញមកឆាប់ៗហ៎ ។
ស្ដេចយាងរកសព្វទាំងកៀនកោះ ឥតមានបន្ទោះសល់ត្រង់ណា
ពុំឃើញមាតានឹងបិតា ទើបស្ដេចយាត្រាត្រឡប់វិញ ។
បង្គាប់ឲ្យអស់ពលសេនា ទាំងពួកយោធាច្រើនពាសពេញ
ដើររកក្នុងព្រៃក័យខ្វល់ខ្វាញ់ ខ្វះថាវើយអញរកខាងនេះ ។
ឯងរកខាងនោះចុះអាអ៊ឹង អាព្រំអាព្រឹងប្រឹងមើលសេះ
អាធុងអាថាំងធ្វើមាត់ស្តុះ អាប្រឹងអាប្រុះវេះខ្វាបខ្វា ។
អាសោមអាសៅដំបៅលេច ដើរធ្វើតិចៗមិនបានការ
ចាំងបោតចាំងបោតប៉ះបន្ទា ស្រែកថាអ្នួយយ៉ាជួយអញផង ។

អាមាត្យមួយចូលរូងក្នុំណា ឃើញហើយចរចាសាកសួរសេង
ថាលោកទាំងពីរនេះឯងហោង ហេតុដូចម្ដេចផងបានជាមក ។
នៅក្នុងទីនេះស្ងាត់ស្ងួនឲ្យឈឹង ក្រែងតួលោកនឹងស្ដេចឲ្យរក
បើដូច្នេះចូលអញ្ជើញមក ខ្ញុំយកទៅថ្វាយមហាក្សត្រា ។
បុរសទាំងពីរឮដូច្នោះ ញ័រក្នុងពន់ពោះឥតឧបមា
អង្វរអាមាត្យដោយពាក្យថា សូមលោកមេត្តាអាណិតខ្ញុំ ។
ខ្ញុំនៅក្នុងព្រៃដោយពិតត្រង់ ខ្ញុំខ្លៅខ្ញុំល្ងង់ដើររកស៊ី
លក់ឧសបន្លែបេះសន្សំ ស្រុកធំមានស្រូវនឹងអង្ករ ។
ខ្ញុំយកទៅដូរហើយនឹងលក់ អំបិលប្រហុកតាមខ្លួនក្រ
ខ្លះឲ្យជាស្រូវខ្លះអង្ករ ខ្លះឲ្យជាល្ងនឹងសណ្ដែក ។
បិញ្ចឹមអាត្មារៀងរាល់ថ្ងៃ ទាំងប្រពន្ធប្ដីប្រឹងទូលរែក
សព្វថ្ងៃខ្ញុំព្រួយចិត្តអនេក កូនបែកចោលបាត់នៅកំព្រា ។
អាមាត្យនាំអ្នកទាំងពីរទៅ ចេញពីព្រៃជ្រៅប្រឹងយាត្រា
ថ្វាយព្រះមហាក្សត្រមានចេស្ដា ចំពោះភក្ត្រាបុត្រទាំងពីរ ។
ស្គាល់ជាក់ជាម្ដាយជាឪពុក ឃើញមុខកាលណាក្សត្រសោកី
ឲ្យអាមាត្យយកទឹកកណ្ដី ស្រោចអ្នកទាំងពីរស្អាតប្រពៃ ។
ឲ្យយកព្រះពស្ត្រល្អពីសេស អប់សឹងគ្រឿងទេសប្រសើរក្រៃ
សម្លៀកបំពាក់រួចស្រេចនៃ ក្សត្រថ្វៃឲ្យឡើងគង់សយនា ។

ទើបស្ដេចសាកសួរតាមដំណើរ ខ្លួនអ្នកនេះតើនៅឯណា
ស្រុកទេសដំបន់នៃការា ចូរថ្លែងប្រាប់ឲ្យខ្ញុំដឹង ។
ប្រុសទាំងពីរប្ដីប្រពន្ធ ភិតភ័យស្ទឹងស្ទន់តែខំប្រឹង
ខំក្រាបពិតទូលថ្វាយដំណាង ដ្បិតស្ដេចចង់ដឹងលំនៅស្ថាន ។

លេខកូត : ..................
លេខបញ្ជី : ..................

ទើបនាងក្រាបទូលតាមដំណើរ បពិត្រប្រសើរក្សត្រកល្យាណ
ខ្ទមខ្ញុំនេះហើយជាគ្រឹះស្ថាន គ្មានញាតិសន្តានគង់ព្រឹក្សា ។
ខ្ញុំមានកូនពីរព្រាត់បាត់ទៅ សព្វថ្ងៃខ្ញុំនៅវែងកំព្រា
តាំងពីព្រាសទៅរងវេទនា គ្មានគ្នាពីរនាក់ប្ដីប្រពន្ធ ។
សព្វថ្ងៃខ្ញុំសោកស្គាំងស្គមអស់ មិនដឹងស្លាប់រស់កូនប្រុសគន់
សូមព្រះបពិត្រមានគុណធ្ងន់ ស្ដេចទុកជីពជន្មឲ្យខ្ញុំផង ។
ស្ដេចឮមាតាថ្លែងដូច្នោះ ព្រឺព្រួចកង់ពោះពេកកន្លង
ស្រក់ទឹកនេត្រាទាំងពីរហោង ទាំងប្អូនទាំងបងសោយសោកា ។
ខ្ញុំទាំងពីរនេះជាកូនពិត សូមលោកពិនិត្យអ្នកមាតា
ខ្ញុំនេះជាបងអនុជា នាំគ្នារត់ចេញចោលអ្នកម្ដាយ ។
ទាំងពីរនេះជាមហេសីខ្ញុំ អភិសេកសុខុមទាំងពីរកាយ
តាំងធ្វើជាកូននៃអ្នកម្ដាយ សូមសុខសប្បាយតរៀងទៅ ។
មូលីសុន្ទរនេះឯងនៃ ជាអគ្គមហេសីអនុជពៅ
ចូរលោកទាំងពីរជ្រាបចាំនៅ ដំណាក់ទៅជាកូនហើយ ។

ក្សត្រទាំងប្រាំអង្គថ្វាយបង្គំ លើកហត្ថប្រណម្យឡើងជាត្រើយ
ទូលថាបពិត្រអ្នកម្ដាយអើយ សូមអ្នកអញ្ជើញទៅនគរ ។
នាហ្មឺនអាមាត្យមុខមន្ត្រី ថ្វាយបង្គំខ្មីច្រើនកុះករ
លើកដៃបន្ទូលសិងឲ្យពរ សូមក្សត្របវរស្ដេចមូលមិត្រ ។
ជួបជុំបុត្រានិងបុត្រី សេនាសេនីយ៍ស្រីស្នំស្និទ្ធ
រីករាយសប្បាយក្រៃពេកពិត ទ្រង់ឫទ្ធិបង្គាប់ពួកសេនា ។
ស្ដេចយាងចេញចាកព្រៃព្រឹក្សហើយ អាមាត្យមុខក្រោយពេញក្រៀបត្រា
សំដៅបុរីពេជសីមា សាកេតនាយណាពារាណសី ។
លុះបានដល់ពាក់កណ្ដាលផ្លូវ ក្សត្រាចមចៅឈប់សេនីយ៍
ទាំងពួកនាហ្មឺនមុខមន្ត្រី ពលសេះដំរីច្រើនក្រៀបត្រា ។
កំសាន្តព្រះកាយសប្បាយចិត្ត ព្រះចៅទ្រង់ឫទ្ធិដ៏ចេស្ដា
ទ្រង់ឲ្យពួករបាំច្រៀងសក្កវា កំសាន្តទ័យាក្នុងព្រឹក្សព្រៃ ។
តស្រីនិងប្រុសក្មេងដេញដំ ព្នសូររងុំពីរោះក្រៃ
សំឡេងស្រីឆ្លើយដូចសត្វរៃ យំនៅក្នុងព្រៃគួរស្រណោះ ។
ប្រុស - ប្អូនអើយតាំងពីបងកើតមក ពន្ទុកមិនដែលឃើញស្រីសោះ
ឥឡូវឃើញហើយបងញ័ររពោះ ពីព្រោះឃើញប្អូនស្រីឯងណា ។
ស្រី - ប្រុសនេះកើតមកពីរន្ធឈើ ខ្ញុំមិនដែលឮអ្នកណាថា
តាំងពីខ្មោចយាយនឹងខ្មោចតា មិនដែលប្រុសណាមិនឃើញស្រី ។

ប្រុស–ប្អូនអើយបងធ្លាប់ឃើញតែញយ ចិត្តបងមិនឲ្យកើតបេតី

បងក្រឡេកឃើញឆោមស្រស់ស្រី គួរឲ្យមេត្រីចាប់ស្នេហា ៗ

ស្រី– ប្អូនព្ទជម្ងឺឈឺញ័រពោះ ឈឺនោះព្រោះតែសរសៃណា

ម្តាយបងពុំបានស្អំពោះពី បានជាឈឺដល់សព្វថ្ងៃ ៗ

ប្រុស–មិនមែនដូច្នោះទេពុំងា បងមែកមេបាណាស្រីថ្លៃ

ថ្ងៃមុនប្អូនឯងលេងចាប់ដៃ មេបាខឹងក្រៃឲ្យញ័រពោះ ៗ

ស្រី– នេះប្រុសថ្មើមខ្មៅដូចក្របី បង្អាប់កេរ្តិ៍ស្រីឲ្យខូចឈ្មោះ

ថាខ្ញុំចាប់ដៃអ្នកឯងនោះ អ្នកប្រុសសាក្សីណាឃើញផង ៗ

ប្រុស–កាលដៃនឹងដៃវាចាប់គ្នា ពុំង៉ានឹងបងពីរនាក់ហោង

បានឃើញជាក់ច្បាស់ប្រាកដផង មេបាគាប់បងទាល់សព្វថ្ងៃ ៗ

ស្រី– រឿងនេះនាងខ្ញុំពុំសុខចិត្ត ធ្វើពាក្យហើយជិតទាំងមេដៃ

ឡើងអ្នកឧកញ៉ាសាលវិនិច្ឆ័យ ឲ្យកាត់សេចក្តីនៃនាងខ្ញុំ ៗ

សុភា– សុភាហៅអ្នកទាំងពីរមក នឹងកាត់សេចក្តីដោយសុខុម

ទារកសាក្សីមកជុំនុំ ផ្ទុំផ្គុំឲ្យឃើញពាក្យខុសត្រូវ ៗ

សុភា– ដែលស្រីចាប់ដៃអ្នកឯងនោះ អ្នកឯងប្រាប់យើងឆាប់ឥឡូវ

ចាប់នៅក្នុងព្រៃឬវាលផ្លូវ សាក្សីអ្នកក្លូវនៅឯណា ៗ

ប្រុស– សូមក្រាបប្រណិបតន៍ព្រះបាទម្ចាស់ ខ្ញុំនៅតូចណាស់ពីកុមារ

ដេញដណ្តើមរើសផ្លែពុទ្រា នាងនេះឯងណាចាប់ដៃខ្ញុំ ៗ

ប្រុស– ខ្ញុំទឹងនាងនេះតែពីរនាក់ ឃើញប្រាកដជាក់ដៃចាប់ចំ
ដៃនាងលូកចាប់លើដៃខ្ញុំ ផ្លែណាធំៗ ដណ្តើមអស់ ៗ
សុភា– សុភាសួរនាងថាពិតឬ ឮឬពុំឮនាងស្រីស្រស់
ចំឡើយខាងប្រុសឆ្លើយទាំងអស់ ពាក្យនោះនាងសុខចិត្តឬទេ ៗ
ស្រី– ពាក្យនេះពិតមែនលោកជាធំ ជាពាក្យឆ្លើយចំរបស់គេ
ឥតមានកៀងក្លាយត្រង់ណាទេ សូមទានរិះរេឈប់លែងក្តី ៗ
សុភា– ត្រូវសងជម្ងឺចិត្តឲ្យស្រេច ធ្វើម្តេចឲ្យបាត់ញ័រក្នុងផ្ទៃ
រឿងនេះខុសព្រោះនាងចាប់ដៃ បានជាគេភ័យលុះឥឡូវ ៗ
ចម្រៀងកំផ្លែងពាក្យស្រីប្រុស ច្រៀងចោទច្រៀងដោះរកខុសត្រូវ
លេងថ្វាយកំសាន្តក្សត្រចមចៅ ដែលស្តេចគង់នៅឥតសប្បាយ ៗ
មូលមិត្តក្រស័ត្រប្រាំពីរអង្គ ដែលទ្រង់ជម្រង់សម្រាកកាយ
កំសាន្តព្រះទ័យលេងសប្បាយ បាត់ក្តៅក្រហាយរំសាយទុក្ខ ៗ
សេនាមន្ត្រីសឹងខ្វាបខ្វប ស្តេចបានប្រកបសេចក្តីសុខ
ចូលក្នុងបុរីទីដែនស្រុក ឥតមានភ័យទុក្ខអ្វីឡើយណា ៗ
ស្តេចបានចូលក្នុងក្រុងសាកេត សប្បាយឥតហេតុទុក្ខភ័យា
ស្តេចនាំមាតានឹងបិតា ស្គាល់ពដះសមាអនុជា ៗ
ទើបរៀបពិធីបុណ្យអភិសេក គុណាតិរេកឲ្យអស្ចារ្យ
ថ្វាយដល់មាតានឹងបិតា ឲ្យដឹងដល់មហាជនទាំងឡាយ ៗ

តាំងជាសម្តេចព្រះផែនដី　　ជនកទាំងពីរព្រួសព្រួសាយ
នាហ្មឺនមន្ត្រីក្សត្រទាំងឡាយ　　ទោះនៅជិតឆ្ងាយដឹងទាំងអស់ ។
ធ្វើបុណ្យដាក់ទានប្រាំពីរថ្ងៃ　　សំពត់អាវស្បៃល្អឥតខ្ចស់
ឲ្យភោជនាហារស　　ដល់មនុស្សទីទាល់ក្រលំបាក ។
ធ្វើបុណ្យហើយស្រេចស្ដេចទ្រង់ត្រាស់ បង្គាប់ជម្រាស់គិតចេញចាក
អាកេតបុរីកុំសម្រាក　　ប្រញាប់តាមពាក្យព្រះឧង្ការ ។
អាមាត្យប្រញាប់ឆាប់រួសរាន់　　ឲ្យទាន់ព្រះទ័យនៃក្សត្រា
ទៅពាពណសីពជរដ្ឋ　　នាំទាំងមាតាបិតាផង ។
ឲ្យស្ដេចបានស្គាល់ពិតប្រាកដ　　កំណត់បុរីស្ដេចរៀមច្បង
ដើម្បីឲ្យពស្ត្រប្រជាផង　　ស្គាល់មាតាហោងនឹងបិតា ។
ទើបស្ដេចអញ្ជើញព្រះជននី　　ជនកទាំងពីរឲ្យយាត្រា
ទៅពាពណសីពជសេមា　　ពួកពលយោធាដង្ហែចេញ ។
ប្រញាប់រួតរះឲ្យបានដល់　　សេនាខ្វាយខ្វល់មូលពាសពេញ
ទៅកាន់ពាពណសីវិញ　　ខ្លួលខ្មាញ់ខ្មីឃ្មាតបរយាត្រា ។
លុះបានទៅដល់ពជបុរី　　វិរាជក្សត្រីអម្ពរណា
ព្រមទាំងនាងចន្ទ័បទុមា　　នាំព្រះមាតាឡើងប្រាសាទ ។
ទាំងព្រះបិតាថ្ងៃប្រសើរ　　ទ្រង់គង់នៅលើទីស្អាងស្អាត
គង់គាល់ត្រៀបត្រាសឹងអាមាត្យ　　ក្រាបក្រោមអភិវាទវិវន្ទា ។

គង់កង់បុរីឥតមានទុក្ខ បានសេចក្ដីសុខគ្រប់ប្រការ
ភោគាព្យាធិអ្វីមួយណា បៀតបៀនក្សត្រាឥតមានឡើយ ៗ
ចំណែកសុវណ្ណអម្ពរស្រី ជាអគ្គមហេសីធំជាត្រើយ
នាងចន្ទទុមមហេសីក្រោយ ពុំមានបុត្រឡើយទាំងពីរប្រាណ ៗ
ចំណែកមូលីសុន្ទរស្រី ឯកអគ្គមហេសីនៃក្សត្រក្សាន្ត
សាកេតបុរីរដ្ឋភជស្ថាន ស្ដេចក៏ឥតមានបុត្រឡើយហោង ៗ
ទាំងពីនគរសឹងគ្មានបុត្រ ស្ដេចគិតក្រែងផុតអ្នកគ្រប់គ្រង
បុរីសីមាទៅមុខផង គ្មានអ្នកគ្រប់គ្រងប្រពៃណី ៗ
ម៉េះសិនគរទឹងសាបសូន្យ សុទ្ធតែគ្មានកូនស្រុកទាំងពីរ
ទាំងពេជ្របុរីកោះគិរី ស្រុកយក្សទាំងពីរក៏អន្តរាយ ៗ
នគរទាំងប្អូនសំសូន្យសោះ យើងគ្មានកូនប្រុសប្រកបកាយ
ផុតពូជត្រកូលយើងទាំងឡាយ សម្បត្តិខាតខ្លាយវិនាសអស់ ៗ
ព្រះចៅទាំងពីរព្រះទ័យព្រួយ ព្រោះគ្មានកូនមួយគ្រងរាជ្យស្មោះ
ដំណាតទៅទឹងសូន្យសោះ ផុតអស់ត្រកូលពូជពង្សា ៗ
ទើបស្ដេចប្រជុំពួកព្រាហ្មណ៍ព្រិល ទឹងបុរោហិតបារគូណា
មូលមិត្តជួបជុំមកគ្រៀបគ្រា តាមព្រះឱង្ការបន្ទូលហៅ ៗ
ពួកព្រាហ្មណ៍អង្គុយតាល់គ្រៀបគ្រា ឯអង្គព្រះមហាក្សត្រចមចៅ
ស្ដេចសួរពួកព្រាហ្មណ៍ដោយចៅអើ ព្រាហ្មណ៍អើយម្ដេចទៅបុរីយើង ៗ

បើគ្មានកូនមួយនឹងតវង្ស ត្រកូលពូជពង្សស្ដេចបានថ្កើង
ធ្វើម្ដេចឲ្យបាននគរយើង ឲ្យបានរុងរឿងអង្វែងទៅ ៗ
ព្រាហ្មណ៍ព្រិឈបានស្ដាប់ព្រះបន្ទូល ពីវង្សត្រកូលព្រះចមចៅ
ព្រាហ្មណ៍ក៏ក្រាបទូលតាមដោយនូវ ទំនាយតាមផ្លូវក្បួនបុរាណ ៗ
ទំនាយទាយថាៈពីនេះទៅ ព្រះចៅនឹងបានសុខថ្កើងថ្កាន
ទេវបុត្រច្យុតចុះចាកស្ថាន ត្រូវបានបុត្រប្រុសបីព្រះអង្គ ៗ
តែថាឲ្យស្ដេចទ្រង់ធ្វើបុណ្យ បំណាយទ្រព្យធនដោយផ្ចិតផ្ចង់
រំលឹកនឹកដល់គុណព្រះសង្ឃ ប្រសើរសីលទ្រង់ជាស្រែបុណ្យ ៗ
ទើបស្ដេចឲ្យរៀបធ្វើពិធី តាមព្រះវេណីពីជាន់មុន
នគរទាំងពីរតាំងបន់ស្រន់ នឹកដល់ព្រះគុណព្រះកោសីយ៍ ៗ
ទ្រង់លើកហត្ថប្រាថ្នាផ្សង សូមដូចបំណងក្នុងបុរី
សូមឲ្យបានបុត្រប្រាកដខ្មី បានដូចសេចក្ដីខ្ញុំប្រាថ្នា ៗ
សហស្សយន៍ព្រះកោសិន្ទ ជាគូគឺអង្គព្រះឥន្ទ្រា
ជាស្ដេចទេវតាគង់នៅនា ស្ថានត្រ័យត្រឹង្សវិមានក្ដី ៗ
ឬទាំងសោឡសមហាព្រហ្ម ដែលលោកជាធំក្នុងលោកិយ៍
សូមលោកជួយដល់អញខ្ញុំខ្មី ឲ្យដូចសេចក្ដីខ្ញុំសច្ចា ៗ
កាលណោះសម្ដេចព្រះកោសិន្ទ ព្រះឥន្ទគង់នៅលើអាស្នា
រំជួលក្ដៅក្តួលទីក្រឡា កម្ពលសិលាល្អប្រែពៃ ៗ

ទើបស្តេចទ្រង់បើកទិព្វចក្ខុ   សំដៅលោកាភពផែនដី
ឃើញពីរក្សត្រាព្រួយព្រះទ័យ   អង្គព្រះសហស្សន័យន៍ជ្រាបកិច្ចការ ៗ
ស្តេចពីរព្រះអង្គចង់បានបុត្រ   ព្រោះភ័យក្រែងផុតពូជពង្សា
បានជាធ្វើបុណ្យហើយប្រាថ្នា   ឲ្យបានបុត្រាដូចបំណង ៗ
ព្រះឥន្ទ្រផ្ទើកផ្ទោះហោះឡើងទៅ   សំដៅតុសិតពិភពហោង
សូមតាននិមន្តទេវបុត្រផង   តាមដោយបំណងមនុស្សលោក ៗ
និមន្តឲ្យបានបីព្រះអង្គ   ពីរគង់ពារាណសីមានជោគ
មួយអង្គសាកេតបុរីលោក   ឥតមានសោកក្រោកប្រសើរក្រៃ ៗ
ទេវបុត្រច្យុតតាំងបីអង្គ   សំដៅចុះត្រង់មនុស្សលោកនៃ
ពីរអង្គយាងចូលទៅកាន់ផ្ទៃ   ក្រុងពារាណសីបុរីស្ថាន ៗ
ចាប់ផ្ទៃសុវណ្ណអម្ពរណា   ចន្ទបទុមាស្រស់កល្យាណ
ឯអង្គក្សត្រីទាំងពីរប្រាណ   កល្យាណនាងបានបុត្រដូចគ្នា ៗ
ព្រះឥន្ទនាំទេវបុត្រមួយអង្គ   តម្រង់បុរីសាកេតណា
ចរចុះកាន់ផ្ទៃនៃធីតា   មហេសីក្សត្រាអនុជនាថ ៗ
ថ្ងៃងពីនិម្មិតនាងទាំងបី   ឃើញចន្ទ្ររស្មីភ្លឺព្រោងព្រាត
ធ្លាក់ចូលមកដល់ក្នុងប្រាសាទ   នាងនាថទទួលចាប់ដោយដៃ ៗ
ស្រាប់តែនាងភ្ញាក់ចាកនិទ្រា   ធីតានឹកក្នកក្នុងដួងថៃ
ថា ឱ! ព្រះចន្ទ្រនៅក្នុងដៃ   គំពុងអាល័យបាត់សូន្យឈឹង ៗ

ទើបនាងក្រាបទូលព្រះស្វាមី បពិត្របក្រីជាពំនឹង
ពំនាក់ដល់ខ្ញុំជាទីពឹង ពេលនឹងនិម្មិតប្លែកសម៉េះ ៗ
សុបិននិម្មិតនាងទេវី នគរទាំងពីរគិតវេរះ
ទូលព្រះស្វាមីបើដូច្នេះ សូមព្រះជម្រះពិចារណា ៗ
ទើបស្ដេចឲ្យហៅពួកព្រាហ្មណ៍ព្រឹទ្ធ ឲ្យត្រិះរិះគិតសព្ទធីតា
និម្មិតបែបនេះល្អឬថា អាក្រក់ទេណាព្រាហ្មណ៍ទាំងឡាយៗ
ឯព្រាហ្មណ៍ទំនាយទាយតាមក្បួន ដោយនូវសំនួនលេខនិយាយ
ដំណាក់ទៅខាងមុខឆ្ងាយ នឹងបានសប្បាយក្នុងបុរី ៗ
លង់លុះប្ដូរយារអង្វែងទៅ គម្រប់គ្រប់ទសមាសាខែ
នាងទ្រង់ប្រសូតិរាជបុត្រថ្លៃ ដោយគួទីទៃរៀងកល់ប្រាណ ៗ
ឯនាងសុវណ្ណអម្ពរស្រី ប្រសូតិបុត្រខ្ចីប្រុសកល្យាណ
រូបល្អឆើតឆាយប្រៀបពុំបាន ដូចកែវសុរិកានរស្មីប្រាល ៗ
ឯចន្ទ៍បទុមស្រស់ប៉ប្រៃ ប្រសូតិបុត្រថ្លៃប្រុសត្រកាល
បានជ្រាបដល់អង្គព្រះភូបាល ព្រះទ័យស្រើបស្រាលចង់ឃើញបុត្រៗ
ទើបស្ដេចឡើងលើប្រាសាទជ័យ អម្ពរស្រីថ្លៃមុនបំផុត
ស្ដេចទ្រង់ក្រឡេកឃើញរាជបុត្រ ស្រឡាញ់ស្ទើរស្លុតព្រះហឫទ័យ ៗ
ត្រឡប់កាន់ទីប្រាង្គប្រាសាទ ប្រសើរស្អាងស្អាតបទុមស្រី
ឃើញព្រះរាជបុត្រប្រាកដខ្ចី ក្សត្រថ្លៃត្រេកអរផុតឧបមា ៗ

លុះដល់គំរប់គ្រប់បីថ្ងៃ    បក្រីទ្រង់ត្រាស់ព្រះឱង្ការ
ឲ្យហៅព្រាហ្មណ៍ព្រឹទ្ធមកត្រៀបត្រា    ថ្វាយនាមបុត្រណាទាំងពីរអង្គ ៗ
ឯបុត្រសុវណ្ណអម្ពរនោះ    ប្រាកដនាមឈ្មោះតាមព្រះវង្ស
សុវណ្ណឯកានាមកើតទ្រង់    ជាអង្គរាជបុត្របងបំផុត ៗ
ឯបុត្រនាងបន្ទន់បទុមា    ប្រាកដនាមថាដោយសម្មតិ
បទុមឯកាពិតប្រាកដ    តាមដោយបែបបទពីរពង្ស ៗ
សាកេតបុរីរាជធានី    ទើបប្រសូត្ររាជបុត្រា
ប្រុសប្រសើរក្រៃល្អស្អាង    ក្សត្រាត្រេកអរឥតឧបមេយ្យ ៗ
ទ្រង់ត្រាសមានព្រះបន្ទូលថ្លែង    ឱ ! ប្រុសនេះឯងស្មើដួងខែ
ឱពុកចាំមើលអ្នកសព្វថ្ងៃ    ឱរសថ្មើមថ្ងៃមកដល់ហើយ ៗ
លុះគំរប់គ្រប់ទិនទិវា    រាត្រីកាលណាពុំលង់ឡើយ
បានបីថ្ងៃស្រេចក្សត្រត្រាណត្រើយ    ឲ្យថ្វាយនាមហើយដល់រាជបុត្រ ៗ
ឈ្មោះព្រះអនុជសុន្ទររាជ    បរិត្ថានបរិញ្ញាបទបំផុត
ព្រះនាមរាជបុត្រពិតប្រាកដ    ទ្រង់មិនឲ្យផុតរាជវង្ស ៗ
នគរទាំងពីរបានចំរើន    រុងរឿងបារមីព្រះចេស្តា
អំណាចផ្សាយទៅគ្រប់សីមា    នាំអស់សួយសារចូលមកថ្វាយ ៗ
ឯរាស្ត្រប្រជានៅក្នុងរដ្ឋ    សម្បូណ៌សម្បត្តិផងទាំងឡាយ
មាសប្រាក់កែវកង់មិនខ្វះបាយ    សប្បាយសម្បូណ៌ពោរពាសពេញ ៗ

សព្វសាស្ត្រដទៃធ្វើជំនួញ　លក់ដូរវៀនខ្លួនដើរចូលចេញ
ពាណិជចេញជួញបានចំណេញ　ខ្លះទិញត្រឡប់ទៅនគរ ៗ
សឹងសុខសប្បាយឥតទុក្ខភ័យ　ក្សត្រពាសទីទៃច្រើនឈូធរ
ដោយបុណ្យបារមីក្សត្រកូធរ　សុខសាន្តកុះករក្នុងបុរី ៗ
រឿងនេះសូមស្ទះត្រឹមនេះហើយ　លោកអើយខ្ញុំបានបញ្ចប់ស្តី
ទោះក្មេងទោះចាស់ទឹងប្រុសស្រី　បានដឹងសេចក្តីរឿងនេះណា ៗ
សូមលោកកុំសើចយំទឹងខ្ញុំ　មិនសូវចេះចាំពាក្យកាព្យា
ខ្ញុំទើបរៀនតែងរឿងនេះណា　លើសលស់អក្ខពដូចម្តេចក្តី ៗ
ខ្ញុំបាទសូមទោសលោកអ្នកប្រាជ្ញ　ដែលលោកអង់អាចចេះបាលី
ដែលចេះចាំច្រើនពួកកវី　ជម្រះសេចក្តីឲ្យខ្ញុំផង ៗ
រឿងនេះចែងចប់តែប៉ុណ្ណេះ　មិនបានវែងឆ្ងាយទៅទៀតហោង
ព្រោះតែងកាព្យឃ្លោងនៅច្រើនខ្គង　ល្បិចល្បងប្រាជ្ញាមិនសូវប៉ិន ៗ
ហេតុនេះខ្ញុំកាត់ឲ្យនៅខ្លី　សេចក្តីចេះស្ទើរមិនបានជ្អឹន
ណ្ហើយប៉ុណ្ណឹងហើយបង្អង់សិន　មុនប៉ុនសុំឲ្យចប់ទៅហោង ៗ

ចប់

ជឹង ង្ជួន ហ្សាត

លេខ ៣០ ស្ទួន វិថី ប៉ាស្ទ័រ

ភ្នំពេញ

១០៛ រោងពុម្ពសិង្ហ